**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២

**សូមផ្ញើជូន**

**ឯកឧត្តម KISHI NOBUO រដ្ឋមន្ត្រីក្រសួងការពារប្រទេសជប៉ុន**

(ទីក្រុងតូក្យូ)

**ឯកឧត្តមជាទីរាប់អាន!**

ខ្ញុំមានអារម្មណ៍រន្ធត់ចិត្តយ៉ាងខ្លាំង និងសោកសៅជាពន់ពេក ដែលទទួលបានព័ត៌មានអំពីមរណភាពរបស់ឯកឧត្តម **អាបេ ស៊ីនហ្សូ** អតីតនាយករដ្ឋមន្ត្រីជប៉ុន ដែលត្រូវជាបងប្រុសបង្កើតរបស់**ឯកឧត្តម** ដោយសារការធ្វើឃាតទាំងកណ្តាលថ្ងៃ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២។

តាងនាមឱ្យនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុត និងសមានចិត្តដ៏ជ្រាលជ្រៅជូនចំពោះ**ឯកឧត្តម** និងតាមរយៈ**ឯកឧត្តម** ជូនចំពោះក្រុមគ្រួសារសពចំពោះការបាត់បង់ដ៏ធំធេងនេះ។ សមានចិត្ត និងការបួងសួងរបស់យើងខ្ញុំស្ថិតនៅជាមួយឯកឧត្តម នៅក្នុងកាលៈទេសៈដ៏សោកសង្រេងនេះ។

ឯកឧត្តម **អាបេ ស៊ីនហ្សូ** ជារដ្ឋបុរសជប៉ុនលេចធ្លោមួយរូប ដែលត្រូវបានគេទទួលស្គាល់ និងលើកសរសើរយ៉ាងទូលំទូលាយចំពោះភាពជាអ្នកដឹកនាំប្រកបដោយសមត្ថភាព ក្នុងការជំរុញវឌ្ឍនភាពរបស់ជប៉ុន និងការចូលរួមចំណែកយ៉ាងសកម្មដល់សន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ និងពិភពលោកទាំងមូល។ ក្នុងនាមជាមិត្តល្អយូរលង់របស់កម្ពុជា ឯកឧត្តម **អាបេ ស៊ីនហ្សូ** បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក្នុងការលើកកម្ពស់ទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា និងជប៉ុនបន្ថែមទៀត នៅក្នុងអាណត្តិជានាយករដ្ឋមន្ត្រីរបស់ឯកឧត្តម ក្នុងនោះរួមទាំងការលើកកម្រិតកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យទៅជាដៃគូយុទ្ធសាស្ត្រ កាលពីឆ្នាំ២០១៣។ ឯកឧត្តម **អាបេ ស៊ីនហ្សូ** នឹងនៅតែទទួលបានការនឹករលឹកយ៉ាងខ្លាំង ហើយស្នាដៃរបស់គាត់នឹងត្រូវបានចងចាំជារៀងរហូត។

សូម **ឯកឧត្តម រដ្ឋមន្ត្រី** ទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**